# ការចិញ្ចឹមគោជាលក្ខណៈគ្រួសារ

## សេចក្តីផ្តើម

ការចិញ្ចឹមគោជាលក្ខណៈគ្រួសារចាំបាច់យើងត្រូវដឹងពីបច្ចេកទេសនៃការចិញ្ចឹមដើម្បីជួយថែរក្សាគោឱ្យមានសុខភាពល្អ និងជួយជាកម្លាំងអូសទាញសម្រាប់ប្រើប្រាស់ឱ្យបានយូរអង្វែង ព្រោះគោជាសត្វមានប្រយោជន៍ដ៏សំខាន់ដូចជាៈ

- ជាកម្លាំងអូសទាញក្នុងការងារកសិកម្ម
- ផ្តល់សាច់ និង ទឹកដោះសម្រាប់ជាអាហារ និង ជម្រុញការលូតលាស់របស់សារពាង្គកាយ
- សម្រាប់ផលិតកូន និង ទុកបន្តពូជ
- ផ្តល់លាមកសម្រាប់យកទៅធ្វើជាជីកំប៉ុស្តិសម្រាប់ដាក់ស្រែចំការ ដំណាំផ្សេងៗដើម្បីបង្កើនទិន្នផល
- ផ្តល់ជាស្បែកសម្រាប់ធ្វើឧបករណ៍ផ្សេងៗ ដូចជា កាតាប ស្បែកជើង ខ្សែក្រ៉ាត្រធ្វើស្គរធំជាដើម។
- ជាពិសេសពេលថ្មីនេះ គេយកលាមកគោលាយជាមួយទឹក រួចបញ្ចូលបង្គន់ជីវឧស្ម័ន ដើម្បីយកឧស្ម័នសម្រាប់ដុតចំអិនអាហារ។

**ដើម្បីឱ្យការចិញ្ចឹមគោទទួលបានជោគជ័យ យើងត្រូវយកចាប់អារម្មណ៍លើចំណុចសំខាន់មួយចំនួនដូចជាៈ**

- ជម្រក ឬ ក្រោល
- ការជ្រើសរើសពូជ
- ចំណី និង ការផ្តល់ចំណី
- ការថែទាំ និងការការពារជម្ងឺ
- ជម្ងឺ និង ការព្យាបាល

## ១- សំណង់ក្រោល ឬ ជម្រក

- **ទីកន្លែងៈ** ត្រូវសង់នៅលើដីទួលមានខ្យល់អាកាសចេញចូល និង ស្រួលបង្ហូរទឹក ហើយត្រូវនៅក្រោមខ្យល់ដើម្បីកុំឱ្យធុំក្លិន។
- **ទិសៈ** ត្រូវសង់ក្រោលគោ-ក្របី បណ្តោយថ្ងៃ។
- ***របៀបសង់ៈ*** កម្រាលក្រោលត្រូវមានចំណោទដើម្បីងាយស្រួលបញ្ចេញទឹក
    - ❖ **ផ្ទៃក្រឡាៈ**

- ➢ គោ ក្របី ញី ៤ ម² ក្នុង ១ ក្បាល
- ➢ មេ គោ ក្របី បំបៅកូន: ៨-៩ ម² ក្នុង ១ ក្បាល
- ➢ កូនគោ ក្របី: ២-២.៥ ម² ក្នុង ១ ក្បាល

❖ **កម្ពស់ក្រោលៈ**

- ➢ គោ ក្របី ឈ្មោល: ១.៤-១.៦ ម² ក្នុង ១ ក្បាល
- ➢ គោ ក្របី ញី: ១-១.២ ម² ក្នុង ១ ក្បាល ។

- ត្រូវមានទ្រុងសម្រាប់ដាក់ស្មៅ ចំបើងដើម្បីទុកឱ្យគោ ក្របី ស៊ីបន្ថែម (បណ្ដោយ: ១.៥ម៉ែត្រ ទទឹង: ១ម៉ែត្រ កម្ពស់: ០.៥ម៉ែត្រ)ត្រូវមានរណ្ដៅ រឺ រោង សម្រាប់ដាក់លាមក សង់ឱ្យឆ្ងាយពី ក្រោល (បណ្ដោយ: ៤ម៉ែត្រ ទទឹង: ២ម៉ែត្រ កម្ពស់:០.៧ម៉ែត្រ) ។



## ២- ការជ្រើសរើសពូជគោ

- អំពីរូបរាង: មានមាឌធំ មានភាពរហ័សរហួន ស្លូត ។
- ផ្នែកដទៃទៀតៈ
  - ➢ **ក្បាលៈ** ធំល្មមតែវែង ថ្ងាស់ទូលាយ មាត់ទូលាយ ច្រមុះសើម ស្លឹកត្រចៀកធំល្មម ធ្មេញសស្មើ ជិតគ្នាប្រេះស្រាំ ស្នែងស្មើ ។

- **ក និងដងខ្លួន:** កវែងល្មម ទ្រូងទូលាយ ស្មាទូលាយ ខ្នងវែងត្រង់ ឬកោងឡើងលើបន្តិច ឆ្អឹង ជំនីរ ធំមូល គូទទូលាយ។
- **ជើង:** ជើងទាំងបួនធំត្រង់ ជើងមុខទាំងពីរឃ្លាតត្រង់គ្នា ក្បាលជង្គង់មូល ភ្លៅក្រោយទាំងពីរ ធំវែង ក្រចកជើងជិតរឹងមាំ។
- **កន្ទុយ:** ធំ
- **ស្បែក:** រលោង ស្តើងល្មម រោមរាបជាប់ស្បែក
- **ប្រដាប់បន្តពូជ:**
  - គោ ក្របី ឈ្មោល មានពងទាំងពីរធំស្មើ
  - **គោញី:** ក្រសោមដោះធំ សរសៃឈាម លើដោះលេចចេញច្បាស់ ក្បាលដោះធំស្មើ ឃ្លាតពីគ្នា។



កន្ទ្រាមដោះធម្មតា



ពងស្វាសដែលមានទម្រង់ល្អ